## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ: ១៧៦ ប្រក

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៧

# ប្រកាស
## ស្តីពី
## តួនាទីភារកិច្ច និង រចនាសម្ព័ន្ធរបស់នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិវិទ្យា

********

### រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-តាមសំណើររបស់អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ

### ស ម្រេ ច

**ប្រការ១.-**

នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិជាអង្គភាពស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គនាយកដ្ឋានបេតិកភណ្ឌនៃក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ។

**ប្រការ២.-**

នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិវិទ្យាមានតួនាទី និង ភារកិច្ច ដូចតទៅ:

-ស្រាវជ្រាវ រុករកកំណត់ ទីតាំង និង ចុះបញ្ជីទីតាំងនៃស្ថានីយបុរេប្រវត្តិ និងប្រវត្តិសាស្ត្រដែលកប់ក្នុងដី និងក្រោមទឹក ។

-ធ្វើកំណាយស្របច្បាប់លើស្ថានីយមួយចំនួន ដែលមានសារសំខាន់ក្នុងការយល់ ដឹងពីសង្គម និងវប្បធម៌សម័យបុរាណ ។

-ធ្វើការវិភាគរាល់វត្ថុបុរាណ ដែលជីកបានពីស្ថានីយដែលមានប្រភពច្បាស់លាស់

-ផ្សព្វផ្សាយនូវពត៌មាន ដែលស្រាវជ្រាវរកឃើញពីកំណាយស្របច្បាប់ដើម្បីចែករំលែកចំណេះដឹងមន្ត្រីក្រសួង និង

បញ្ជូនវគ្គទូទៅ ។

-ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

ប្រការ៣.-

នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ៤.-

នាយកដ្ឋានបុរាណវិទ្យានិង បុរេប្រវត្តិមាន ការិយាល័យចំនួនប្រាំ គឺ:

- ការិយាល័យ រដ្ឋបាល
- ការិយាល័យ ស្រាវជ្រាវ និង រុករក
- ការិយាល័យ វិភាគ និង ពិសោធន៍
- ការិយាល័យ បញ្ជីសារពើភណ្ឌ
- ការិយាល័យ បោះពុម្ព និង ផ្សព្វផ្សាយ

ការិយាល័យនីមួយៗមានប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អង្គការលេខនាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិជាឧបសម្ព័ន្ធនៃប្រការនេះ ។

ប្រការ៥.-

ការិយាល័យនិមួយៗមានភារកិច្ចដូចតទៅ :

១- <u>ការិយាល័យ រដ្ឋបាល</u>

-គ្រប់គ្រងការងាររដ្ឋបាល

-គ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការ ពលករអណ្តែត មន្ត្រីជាប់កិច្ចសន្យា និងបណ្តុះបណ្តាលបង្កើនមុខជំនាញ ។

-សរុបលទ្ធផលការងារធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆ្នាំ និង គ្រប់គ្រងឯកសារគ្រប់ប្រភេទ ។

-ធ្វើផែនការ យុទ្ធសាស្ត្រ និងកម្មវិធីការងារ

-គ្រប់គ្រងចំណូល-ចំណាយ បេឡវិពលកម្ម និងកសាងថវិកាប្រចាំឆ្នាំ

-គ្រប់គ្រងសំភារៈចលនៈទ្រព្យ និង អចលនៈទ្រព្យរបស់រដ្ឋ

២- <u>ការិយាល័យ ស្រាវជ្រាវ និងរុករក</u>

-ចុះធ្វើកំណាយស្របច្បាប់លើស្ថានីយបុរាណមួយចំនួនដើម្បីយល់ដឹងពីអតីតកាលនៃសង្គម និង វប្បធម៌របស់មនុស្សក្នុងសម័យបុរាណ ។

-ការពារទីលានជីករុករកបុរាណវត្ថុ និង សម្បត្តិវប្បធម៌ដែលរកឃើញ ។

-គ្រប់គ្រងមជ្ឈមណ្ឌលបុរាណវិទ្យាទាំងអស់

-ពិនិត្យ និងផ្តល់យោបល់ជូនស្ថាប័នមានសមត្ថកិច្ចលើរាល់សំណើរសុំសិក្សាស្រាវជ្រាវ និង កំណាយ ។

-រៀបចំលិខិតបទដ្ឋានផ្សេងៗដើម្បីធានាដល់ការ ការពារស្ថានីយបុរាណ ។

៣- ការិយាល័យ វិភាគ និង ពិសោធន៍

-គ្រប់គ្រងមន្ទីរពិសោធន៍ និងធ្វើការសិក្សាវិភាគលើវត្ថុបុរាណដែលបានពីស្ថានីយដែលមានប្រភពច្បាស់លាស់

-ជួសជុល និង ធ្វើការពិសោធន៍វត្ថុសិល្បៈ

-ពិនិត្យលើវត្ថុបុរាណដែលនិងស្នើសុំយកទៅធ្វើការពិសោធន៍នៅក្រៅប្រទេស

៤- ការិយាល័យ បញ្ជីសារពើភណ្ឌ

-ស្រាវជ្រាវ ចុះរុករកកំណត់ទីតាំង និង ចុះបញ្ជីរាល់ស្ថានីយបុរាណ និង បុរេប្រវត្តិទាំងលើដី កប់ក្នុងដី និង ក្រោមទឹក ។

-បញ្ចូលទិន្ន័យបុរាណស្ថានទៅក្នុងប្រព័ន្ធពត៌មានវិទ្យា

-ធ្វើការវាយតំលៃទៅលើស្ថានីយនិមួយៗ ក្នុងការសិក្សា និងចាត់វិធានការ ការពារ និង អភិរក្ស ដោយសហការជាមួយនាយកដ្ឋានគាំពារ និង អភិរក្សសំណង់បុរាណ ។

៥- ការិយាល័យ បោះពុម្ព និង ផ្សព្វផ្សាយ

-បោះពុម្ព និង ផ្សព្វផ្សាយ ពត៌មានដែលជាលទ្ធផលនៃការស្រាវជ្រាវពីស្ថានីយបុរាណ

-រៀបចំកម្មវិធីបណ្តុះបណ្តាល និង អប់រំប្រជាជនពីសារសំខាន់នៃស្ថានីយបុរាណ និង បេតិកភណ្ឌជាតិ

-ចងក្រង និង រក្សាឯកសារទាក់ទងនឹងការធ្វើកំណាយ និង ស្ថានីយបុរាណ ។

ប្រការ៦.-

នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិជាអង្គភាពអនុវត្តរបបហិរញ្ញវត្ថុរដ្ឋបាលសាធារណៈ ។

ប្រការ៧.-

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះចាត់ទុកជានិរាករណ៍ ។

ប្រការ៨.-

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃ សាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈប្រធាន នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវ ទទួលអនុវត្ត ប្រកាសនេះតាមភារកិច្ច រៀងៗខ្លួនពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីស្តីទី

ហ៊ឹម ឆែម

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

"ដើម្បីជូនជ្រាបជាពត៌មាន"

-ដូចប្រការ៨

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៧៤/វប្រ.ក.... ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៧...

## អង្គការលេខរបស់នាយកដ្ឋាន បុរាណវិទ្យា និង បុរេប្រវត្តិវិទ្យា

